សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

# សេចក្តីប្រកាសព័ត៌មាន
# របាយការណ៍ឯករាជ្យបង្ហាញថា វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា
# ជួយជំរុញគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

***ភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤៖*** ការសិក្សាអំពីការវាយតម្លៃលើផលជះដែលត្រូវបានធ្វើឡើងដោយឯករាជ្យបានបង្ហាញថា វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមិនត្រឹមតែជាម៉ាស៊ីនជួយជំរុញសេដ្ឋកិច្ចដ៏រឹងមាំប៉ុណ្ណោះទេ តែថែមទាំងជាកម្លាំងចលករជួយជំរុញប្រទេសកម្ពុជាដើរឆ្ពោះទៅរកការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ផងដែរ។

របាយការណ៍ដែលរៀបចំឡើងដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងអនុវត្តដោយក្រុមហ៊ុនស្រាវជ្រាវអន្តរជាតិ M-CRIL បានសិក្សាស៊ីជម្រៅអំពីឥទ្ធិពលរបស់មីក្រូហិរញ្ញវត្ថុក្នុងការជួយផ្លាស់ប្តូរទិដ្ឋភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់កម្ពុជា ដោយបង្ហាញឱ្យឃើញនូវសមិទ្ធិផលរបស់វិស័យ និងបញ្ហានានាដែលកើតមានឡើងស្របជាមួយនឹងការចូលរួមចំណែករបស់វិស័យនេះលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## លទ្ធផលរកឃើញសំខាន់ៗពីការសិក្សា៖

ការសិក្សាអំពីការវាយតម្លៃលើផលជះ ដែលបានធ្វើឡើងយ៉ាងយកចិត្តដាក់ជាមួយអតិថិជនជាង ៣២០០ នាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជ្រើសរើសមកពីភូមិជាង ៤៥០ភូមិក្នុងខេត្តចំនួន ១០ខេត្ត បានបង្ហាញផលជះចម្រុះនៃវិស័យមីក្រូហិរញ្ញវត្ថុទៅលើជីវិតរស់នៅរបស់ប្រជាជនកម្ពុជា។

ការសិក្សាបានបង្ហាញថា ពីរភាគបី (២/៣) នៃសំណាក បានរាយការណ៍ពីភាពប្រសើរឡើងក្នុងជីវិតរបស់ពួកគេ ដោយ ៣១% ទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចច្រើននិងមានជីវភាពល្អប្រសើរជាងមុន ខណៈដែល ៣៦% ផ្សេងទៀតបានរាយការណ៍ពីភាពល្អប្រសើរនូវជីវភាពខ្លះ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ។ នេះគឺជាតឹកតាងបញ្ជាក់ថា មីក្រូហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាតាមរយៈការអនុញ្ញាតឱ្យគ្រួសារដែលមានចំណូលទាបជាច្រើនទទួលបានកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

## ទស្សនៈវិស័យរបស់ លោក សុខ វឿន ប្រធានក្រុមប្រឹក្សាភិបាលសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា៖

**លោក សុខ វឿន ប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា** បានអត្ថាធិប្បាយអំពីលទ្ធផលរកឃើញនៃរបាយការណ៍នេះថា៖ «ផលជះដែលជួយឱ្យមានការផ្លាស់ប្តូរនៃវិស័យមីក្រូហិរញ្ញវត្ថុមិនត្រឹមតែជាផលជះផ្នែកសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគ្របដណ្តប់លើទិដ្ឋភាពសង្គមកម្ពុជាទាំងមូលទៀងផង។ ការសិក្សាស្រាវជ្រាវនេះបញ្ជាក់សារជាថ្មីអំពីតួនាទីរបស់វិស័យមីក្រូហិរញ្ញវត្ថុក្នុងការជំរុញការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម។ ក្នុងនាមសមាគមីក្រូហិរញ្ញវត្ថុកម្ពុជា យើងប្តេជ្ញាយកលទ្ធផលស្រាវជ្រាវនេះដើម្បីបន្តពង្រឹងការចូលរួមចំណែកជាវិជ្ជមានរបស់វិស័យដល់សង្គមរបស់យើង»។

## ការជំរុញគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ស្វែងយល់ពីរបៀបដែលវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកំពុងជំរុញវឌ្ឍនភាពឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសំខាន់ៗ៖

## SDG ១៖ គ្មានភាពក្រីក្រ

**ភាពអាចរកបាននូវសេវាមីក្រូហិរញ្ញវត្ថុ៖** ការសិក្សាបង្ហាញថា មីក្រូហិរញ្ញវត្ថុផ្តល់សេវាជូនអតិថិជនមានរហូតដល់ ៥៨,៦% នៃសំណាក ដោយ ៦៧% បានរាយការណ៍ពីភាពប្រសើរឡើងយ៉ាងច្រើននៃជីវភាពប្រចាំថ្ងៃ។ ចំណុចជាវិជ្ជមាននេះបង្ហាញពីផលជះដ៏មានតម្លៃទៅលើការកាត់បន្ថយភាពក្រីក្រ ជាពិសេសក្នុងចំណោមគ្រួសារក្រីក្រខ្លាំង។

## SDG ២៖ គ្មានភាពអត់ឃ្លាន

**ភាពប្រសើរឡើងនៃជីវិតរស់នៅ និងការទទួលទានអាហារ៖** ភាពប្រសើរឡើងនៃជីវិតរស់នៅ ជាពិសេសក្នុងចំណោមគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ បានរួមចំណែកដល់ការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពចំនុចទី២ ដោយមានត្រឹមតែ ០,៨% នៃសំណាកប៉ុណ្ណោះដែលទទួលរងផលប៉ះពាល់ដោយសាររយៈពេលកាត់បន្ថយអាហារហូបចុកបណ្តោះអាសន្ន។

## SDG ៣៖ សុខភាពល្អ និងសុខុមាលភាព

**គុណភាពជីវិត៖** ការសិក្សាបង្ហាញថា ៦៧% នៃសំណាក ទទួលបានភាពប្រសើរឡើងខ្លះនៃជីវិតរស់នៅរបស់ពួកគេដែលរួមចំណែកដល់សុខុមាលភាពទាំងមូល។ បើទោះជាបញ្ហាប្រឈមនៅតែមានក៏ដោយ ក៏និន្នាការជារួមមានភាពវិជ្ជមាន។

## SDG ៥៖ សមភាពយេនឌ័រ

**ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី៖** មីក្រូហិរញ្ញវត្ថុបានបង្ហាញពីការចូលរួមចំណែកដោយផ្ទាល់ចំពោះសមភាពយេនឌ័រ ដោយចំនួនអ្នកទទួលកម្ចីជាស្ត្រីមានរហូតដល់ ៤៦% ពោលគឺមានច្រើនជាងបុរសដែលមានត្រឹមតែ ៤១% ប៉ុណ្ណោះ។ បញ្ហាប្រឈមក៏ឃើញមានផងដែរទាក់ទងនឹងតួនាទី និងទំនុកចិត្តរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ។

## SDG ៨៖ ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច

**កំណើនសហគ្រិនភាព៖** អ្នកឆ្លើយតបជាស្ត្រី និងបុរសបានរាយការណ៍ពីការប្រើប្រាស់ប្រាក់កម្ចីដើម្បីពង្រីកអាជីវកម្មខ្នាតមីក្រូ និងខ្នាតតូចរបស់ពួកគេ ដែលចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច។ ការរីកចម្រើននៃសហគ្រិនភាពនេះមានភាពស្របតាមស្មារតីនៃ SDG-៨។

## SDG ១០៖ កាត់បន្ថយវិសមភាព

**ផលជះលើវិសមភាព៖** សម្រាប់អតិថិជនមីក្រូហិរញ្ញវត្ថុ ៣១% ដែលបានរាយការណ៍ពីភាពប្រសើរឡើងខ្លាំងនៃជីវិតរស់នៅរបស់ពួកគេ ភាពប្រសើរឡើងខ្លាំងនេះគឺជាការបង្ហាញពីការកាត់បន្ថយវិសមភាព ដែលចូលរួមដោយផ្ទាល់ទៅនឹងគោលដៅគ្មានភាពក្រីក្រ SDG-១។

## SDG ១១៖ ទីក្រុងនិងសហគមន៍ប្រកបដោយចីរភាព និង SDG ១២៖ ការប្រើប្រាស់និងការផលិតប្រកបដោយការទទួលខុសត្រូវ

**ផលជះលើគោលនយោបាយកម្រិតម៉ាក្រូ៖** បើទោះបីជា SDGs ទាំងពីរនេះមានឥទ្ធិពលលើគោលនយោបាយ និងសកម្មភាពនៅកម្រិតមីក្រូ និងមិនអនុវត្តដោយផ្ទាល់ចំពោះសេវាកម្មមីក្រូហិរញ្ញវត្ថុក៏ដោយ ក៏ការសិក្សាស្រាវជ្រាវនេះសង្កត់ធ្ងន់លើ

តួនាទីរបស់វិស័យនេះក្នុងការជំរុញការអនុវត្តការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងការចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

**ចក្ខុវិស័យសម្រាប់អនាគត**

លទ្ធផលរកឃើញលម្អិតនៃរបាយការណ៍ស្តីពីការវាយតម្លៃផលជះនេះបានកំណត់វិស័យមីក្រូហិរញ្ញវត្ថុថាជាកម្លាំងដ៏ខ្លាំងក្លាសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន ដែលស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងជំរុញកំណើនប្រកបដោយបរិយាបន្នក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះក៏បានគូសបញ្ជាក់អំពីតម្រូវការឱ្យមានកិច្ចសហការ និងការប្តេជ្ញាចិត្តជាបន្តក្នុងការកសាងប្រព័ន្ធអេកូហិរញ្ញវត្ថុដែលមានភាពធន់ និងប្រកបដោយនិរន្តរភាពផងដែរ៕

**អំពីសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)**

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) គឺជាអង្គការមិនមែនរដ្ឋាភិបាល និងសមាគមវិជ្ជាជីវៈដែលមានមូលដ្ឋាននៅរាជធានីក្រុងភ្នំពេញ ដែលធ្វើការងារលើកកម្ពស់ការអនុវត្តសេវាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងនិរន្តរភាពសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា។

**អំពីក្រុមហ៊ុន M-CRIL**

ក្រុមហ៊ុន M-CRIL គឺជាក្រុមហ៊ុនស្រាវជ្រាវអភិវឌ្ឍន៍ឯករាជ្យលំដាប់អន្តរជាតិ និងមានឯកទេសខាងផ្នែកវាយតម្លៃមីក្រូហិរញ្ញវត្ថុ ដោយផ្តល់ទិន្នន័យស៊ីជម្រៅនិងមានតម្លៃអំពីផលជះទៅលើសេដ្ឋកិច្ចនិងសង្គមកិច្ចនៃមីក្រូហិរញ្ញវត្ថុទូទាំងពិភពលោក។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងៈ**

លោក កាំង តុងងី ប្រធាននាយកដ្ឋានទំនាក់ទំនងនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) តាមរយៈ hcd@cma-network.org ឬ ០៩៥ ២៦២ ១១១៕